01735235

F71/1/1/10


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

# អនុស្សរណៈអន្តរការិយាល័យ

ផ្ញើជូន៖ ឯកឧត្តម គង់ ស្រីម
ប្រធាន អង្គជំនុំជម្រះតុលាការកំពូល

កាលបរិច្ឆេទ៖ ២៦ កក្កដា ២០២៤

ពី៖ Rosa Maria JIMENEZ SANCHEZ
ប្រធានអង្គភាពបណ្ណសារ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jul-2024, 13:10
CMS/CFO: Sann Rada

ចម្លងជូន៖ ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទី
លោក Knut ROSANDHAUG អនុប្រធានការិយាល័យរដ្ឋបាល

កម្មវត្ថុ៖ បញ្ជីឯកសារដែលបានដកចំណាត់ថ្នាក់ទាំងអស់ ដែលជាលទ្ធផលមកពីការដកចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០២

១. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ អង្គជំនុំជម្រះបានដាក់*សេចក្តីសម្រេចស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២* (**F71/1/1/8**)។

២. នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ អង្គជំនុំជម្រះបានដាក់*ដីកាបង្គាប់អង្គភាពបណ្ណសារស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២* (**F71/1/1/9**) ដែលក្នុងដីកានេះអង្គជំនុំជម្រះបានណែនាំអង្គភាពបណ្ណសារឱ្យដកចំណាត់ថ្នាក់ឯកសារសំណុំរឿង អនុលោមតាមឧបសម្ព័ន្ធជាមូលដ្ឋាន និងស្របតាមសេចក្តីសម្រេច **F71/1/1/8**។ បន្ថែមលើនេះ អង្គជំនុំជម្រះបានតម្រូវឱ្យអង្គភាពបណ្ណសារ "ផ្សព្វផ្សាយបញ្ជីឯកសារទាំងអស់ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈក្រោយពីការដកចំណាត់ថ្នាក់នេះរួច"។

៣. នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ អង្គជំនុំជម្រះបានដាក់ "*ដីកាបង្គាប់ឱ្យផ្សព្វផ្សាយ និងជូនដំណឹងឯកសារដែលត្រូវបានដកចំណាត់ថ្នាក់ និងពុំចាំបាច់ធ្វើការកោសលុបជាសាធារណៈក្នុងសំណុំរឿង*

*០០២*’ **(F88)** តម្រូវឱ្យអង្គភាពបណ្ណសារដកចំណាត់ថ្នាក់ឯកសារចំនួន ៨.៧១៦។ អង្គភាពបណ្ណសារបានបញ្ចប់ការធ្វើចំណាត់ថ្នាក់ឯកសារឌីជីថលឡើងវិញនៅក្នុង ZyLAB នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។

៤. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ អង្គជំនុំជម្រះបានចេញដីកាបង្គាប់លើកទីមួយ **(F89)** និង លើកទីពីរ **(F90)** របស់ខ្លួននៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ *ឱ្យផ្សព្វផ្សាយ និងជូនដំណឹងឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់ទៅជា “សាធារណៈ” ដែលមានការកោសលុបក្នុងសំណុំរឿង ០០២* ដោយតម្រូវឱ្យអង្គភាពបណ្ណសារដកចំណាត់ថ្នាក់ឯកសារចំនួន ១៤.៧០០។ អង្គភាពបណ្ណសារបានបញ្ចប់ការធ្វើចំណាត់ថ្នាក់ឯកសារឌីជីថលឡើងវិញនៃឯកសារជាមូលដ្ឋាននៅក្នុង ZyLAB នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤។

៥. គិតត្រឹមថ្ងៃនេះ អង្គភាពបណ្ណសារបានបញ្ចប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃរាល់ឯកសារពាក់ព័ន្ធទាំងអស់ ដូចបានចងក្រងជាឯកសារខាងក្រោម៖

   ក. **ឧបសម្ព័ន្ធ ក៖** ឯកសារដែលបានដកចំណាត់ថ្នាក់ទៅជាសាធារណៈដោយមិនមានការកោលសុប (៨.៦៥៩ ឯកសារ ស្មើនឹង ៥២.០៩០ ទំព័រ)
   ខ. **ឧបសម្ព័ន្ធ ខ៖** ឯកសារដែលបានដកចំណាត់ថ្នាក់ទៅជាសាធារណៈដោយមានការកោសលុប (១៥.០៥១ ឯកសារ ស្មើនឹង ១៥៩.១១៩ ទំព័រ)

៦. អនុស្សរណៈនេះគឺជាការអនុវត្តរបស់អង្គភាពបណ្ណសារតាមដីការបស់អង្គជំនុំជម្រះ ស្ដីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ និងជាការជូនដំណឹងដល់ភាគីនិងសាធារណជន៕